ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King



ក្រសួងពាណិជ្ជកម្ម
Ministry of Commerce


លេខ ៣០៩ ព.ណ.ប.ស.ស. ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការនាំចូលអង្ករពីបរទេស

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញ និងសេវា
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញប្រកាសលេខ ១៧៨ ពណ.នច ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តទៅរបស់នាយកដ្ឋាននាំចេញ-នាំចូល នៃក្រសួងពាណិជ្ជកម្ម
- យោងតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឲ្យអនុវត្ត នូវការបំពេញបែបបទស្នើសុំនាំចូលអង្ករពីបរទេស ក្នុងគោលបំណងរក្សាបាននូវការធ្វើពាណិជ្ជកម្មដោយសមធម៌ និងអនុលោមភាពជាមួយនឹងវិធានប្រភពដើមទំនិញ។


ឡូត៍លេខ ១៩-៦១ វិថីក្រសួងពាណិជ្ជកម្ម (១១៣បេ), ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ, ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ(៨៥៥)-២៣ ៨៦៦ ៤៦៩
Ministry of Commerce, Lot 19-61, MOC Road (113B Road), Phum Teuk Thla, Sangkat Teuk Thla, Khand Sen Sok, Phnom Penh, Kingdom of CAMBODIA
Phone/Facsimile: (855)-23 866 469

**ប្រការ ២.-**

ក្រុមហ៊ុន ឬអ្នកនាំចូលអង្ករ ត្រូវដាក់ពាក្យស្នើសុំមកក្រសួងពាណិជ្ជកម្ម ដោយបំពេញបែបបទ និងភ្ជាប់ឯកសារ ដូចខាងក្រោម៖

- ពាក្យស្នើសុំដូចមានគំរូ ភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសនេះ
- វិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ឬអាជីវកម្ម ចំពោះករណីស្នើសុំលើកដំបូង (ច្បាប់ថតចម្លង )
- វិក្កយបត្រ (Invoice) និងតារាងវេចខ្ចប់ (Packing List) (ច្បាប់ដើម)
- កិច្ចសន្យាទិញ-លក់ (ច្បាប់ដើម)។

**ប្រការ ៣.-**

រាល់ការនាំចូលអង្ករពីបរទេស ចាំបាច់ត្រូវមានភាពអនុលោមតាមលក្ខខណ្ឌតម្រូវនៃបទដ្ឋានច្បាប់។ ក្រុមហ៊ុន ឬអ្នកនាំចូលអង្ករពីបរទេស ត្រូវមានសំបកវេចខ្ចប់សមស្រប និងត្រូវបោះពុម្ពនូវព័ត៌មានដូចខាងក្រោម៖

-ក្រុមហ៊ុននាំចូល និងអាសយដ្ឋាន

-ក្រុមហ៊ុនផ្គត់ផ្គង់

-ទម្ងន់ (គិតជាគីឡូក្រាម)

-ប្រភព និង

-កាលបរិច្ឆេទផុតកំណត់នៃការប្រើប្រាស់។

**ប្រការ ៤.-**

ក្រោយពីទទួលបានពាក្យស្នើសុំ ក្រសួងពាណិជ្ជកម្មត្រូវផ្តល់ការយល់ព្រមឲ្យនាំចូលអង្ករក្នុងរយៈពេលមិនឲ្យលើសពី០២(ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ។ សុពលភាពនៃការយល់ព្រមឲ្យនាំចូលអង្ករត្រូវមានរយៈពេល ០៣(បី)ខែ គិតចាប់ពីកាលបរិច្ឆេទនៃការអនុញ្ញាត។

**ប្រការ ៥.-**

ក្នុងករណីមានបណ្តឹងតវ៉ា មន្ត្រីជំនាញក្រសួងពាណិជ្ជកម្ម ត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធដើម្បីចុះទៅធ្វើអធិការកិច្ច។ សហព័ន្ធស្រូវ-អង្ករកម្ពុជា អាចផ្តល់ព័ត៌មាន និងចូលរួមសង្កេតការណ៍ តាមការចាំបាច់។

**ប្រការ ៦.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវបានចាត់ទុកជានិរាករណ៍។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

ចម្លងជូនៈ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី ស ខេង
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អគ្គនាយកដ្ឋានកាំកុងត្រូល
- អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
- គ្រប់រដ្ឋបាលរាជធានី-ខេត្ត
- សភាពាណិជ្ជកម្មកម្ពុជា
- សហព័ន្ធស្រូវ-អង្ករកម្ពុជា "ដើម្បីជូនជ្រាប"
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ